ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ០០៧/សណន

# សេចក្តីណែនាំ
## ស្តីពី
## ការឈប់សំរាក របស់មន្ត្រីរដ្ឋបាលស៊ីវិល ក្រសួងមហាផ្ទៃ

ដោយអនុលោមតាមអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកំណត់រយៈពេលបំរើការងារប្រចាំសប្តាហ៍ របស់មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា និង តាមខ្លឹមសារ នៃសំរេចលេខ ៧៣ សរច ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៨២ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីម៉ោងធ្វើការ និង ពេលឈប់សំរាក របស់កម្មាភិបាល បុគ្គលិក កម្មករ និងដើម្បីកំណត់អោយបានច្បាស់លាស់អំពីបែបបទ នីតិវិធី និងសមត្ថកិច្ចក្នុងការអនុញ្ញាតច្បាប់ឈប់សំរាកអោយមន្ត្រីរាជការ ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំ ដល់មន្ត្រី រដ្ឋបាលស៊ីវិល ក្រសួងមហាផ្ទៃ ដូចខាងក្រោម :

### ក. ការឈប់សំរាក

#### ១. ការឈប់សំរាកប្រចាំសប្តាហ៍

មន្ត្រីរដ្ឋបាលស៊ីវិល ក្រសួងមហាផ្ទៃ ត្រូវបានអនុញ្ញាតអោយឈប់សំរាកពីការងាររយៈពេល២ថ្ងៃ ក្នុងមួយសប្តាហ៍គឺ ថ្ងៃសៅរ៍ និង ថ្ងៃអាទិត្យ ។

#### ២. ការឈប់សំរាកដោយមូលហេតុផ្សេងៗ

មន្ត្រីរដ្ឋបាលស៊ីវិល ក្រសួងមហាផ្ទៃ មានសិទ្ធិសុំច្បាប់ឈប់សំរាកពីការងារ ដោយមូលហេតុចាំបាច់មួយចំនួន ដូចបានកំណត់ខាងក្រោម :

- មរណភាព នៃញាតិពន្ធ និង សមាជិកក្រុមគ្រួសារ ក្នុងបន្ទុក
- ព្យាបាលជម្ងឺផ្ទាល់ខ្លួន
- រៀបចំអាពាហ៍ពិពាហ៍កូន ឬ សាមីខ្លួនផ្ទាល់
- លំហែមាតុភាព ( សំរាប់ស្ត្រី ) មិនលើសពី ០៣ខែ ។

#### ៣. ការឈប់សំរាកប្រចាំឆ្នាំ

- មន្ត្រីរដ្ឋបាលស៊ីវិល ក្រសួងមហាផ្ទៃ ត្រូវបានអនុញ្ញាតអោយឈប់សំរាកពីការងារប្រចាំឆ្នាំ ចំនួន ១៥ថ្ងៃ ដោយមានបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំ នៃបៀវត្ស ចំពោះអ្នករាជការណា ដែលបានបំរើការងាររយៈពេល ១២ខែ ពេញ ជាប់រហូត ។

១៩១

- រយៈពេលឈប់សំរាក១៥ថ្ងៃនេះ មិនរាប់បញ្ចូលថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ ( ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ) និង ថ្ងៃឈប់សំរាកទៅតាមប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំនីមួយៗ ដែលបានកំណត់ដោយរាជរដ្ឋាភិបាល និង ការឈប់សំរាកដោយមូលហេតុផ្សេងៗ ដូចបានកំណត់ខាងលើនោះទេ ។

## ខ_ សមត្ថកិច្ច នៃការអនុញ្ញាតច្បាប់

### ១_ ទីស្តីការក្រសួង:

- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានសិទ្ធិអនុញ្ញាតច្បាប់ឈប់សំរាក អោយមន្ត្រីរាជការដូចមានកំណត់ខាងក្រោម :

+ ឈប់សំរាកប្រចាំឆ្នាំ ( ១៥ថ្ងៃ ) :

- មន្ត្រីរដ្ឋបាលស៊ីវិល ចំណុះទីស្តីការក្រសួងមហាផ្ទៃ
- អភិបាល អភិបាលរងខេត្ត ក្រុង
- អភិបាលស្រុក ខណ្ឌ
- ប្រធានអង្គភាពចំណុះរចនាសម្ព័ន្ធសាលាខេត្ត ក្រុង ( ខុទ្ទកាល័យ អគ្គលេខាធិការ ក្រុមអធិការកិច្ច ក្រុមហិរញ្ញវត្ថុ ) ។

+ ការឈប់សំរាកដោយមូលហេតុផ្សេងៗ :

- អគ្គនាយក អគ្គលេខាធិការ អគ្គាធិការ អភិបាល អភិបាលរងខេត្ត ក្រុង មានរយៈពេលចាប់ពី០៤ ថ្ងៃ ឡើងទៅ ។
- មន្ត្រីរដ្ឋបាលស៊ីវិល ចំណុះទីស្តីការក្រសួងមហាផ្ទៃ មានរយៈពេលចាប់ ០៧ថ្ងៃ ឡើងទៅ ។

- អគ្គនាយករដ្ឋបាល អគ្គលេខាធិការ អគ្គាធិការ មានសិទ្ធិអនុញ្ញាតច្បាប់ឈប់សំរាក អោយមន្ត្រីរាជការដូចមានកំណត់ខាងក្រោម :

- អគ្គនាយករង អគ្គលេខាធិការរង អគ្គាធិការរង ប្រធាននាយកដ្ឋាន អធិការ អនុប្រធាននាយកដ្ឋាន អធិការរង ដែលសុំច្បាប់ឈប់សំរាក ក្នុងរយៈពេល ០១ថ្ងៃ ទៅ ០៣ថ្ងៃ ។
- មន្ត្រីរាជការ ក្រោមឱវាទទីស្តីការក្រសួងមហាផ្ទៃ ដែលសុំច្បាប់ឈប់សំរាក ក្នុងរយៈពេល ០៤ថ្ងៃ ទៅ ០៧ថ្ងៃ ។

- ប្រធាននាយកដ្ឋាន អធិការ មានសិទ្ធិអនុញ្ញាតច្បាប់ឈប់សំរាក អោយមន្ត្រីរាជការក្រោមឱវាទទាំងអស់ ក្នុងរយៈពេលមិនលើសពី ០៣ថ្ងៃ ។
- ប្រធានពន្ធនាគារកណ្តាល ( ម១ ម២ ម៣ ) មានសិទ្ធិអនុញ្ញាតច្បាប់ អោយមន្ត្រីរាជការក្រោមឱវាទ ក្នុងរយៈពេលមិនលើសពី ០១ថ្ងៃ ។

### ២_ សាលាខេត្ត ក្រុង:

- អភិបាលខេត្ត ក្រុង មានសិទ្ធិអនុញ្ញាតច្បាប់ឈប់សំរាក អោយមន្ត្រីរាជការដូចមានកំណត់ខាងក្រោម :

+ ឈប់សំរាកប្រចាំឆ្នាំ ( ១៥ថ្ងៃ ) :

- មន្ត្រីរដ្ឋបាលស៊ីវិល ចំណុះសាលខេត្ត ក្រុង ស្រុក ខណ្ឌ ( ក្រៅពីការកំណត់ខាងលើ )

+ ការឈប់សំរាកដោយមូលហេតុផ្សេងៗ :

- អភិបាល អភិបាលរង ស្រុក ខណ្ឌ ប្រធានអង្គភាពចំណុះរចនាសម្ព័ន្ធសាលាខេត្ត ក្រុង ( ខុទ្ទកាល័យ អគ្គលេខាធិការ ក្រុមអធិការកិច្ច ក្រុមហិរញ្ញវត្ថុ ) ដែលបានសុំច្បាប់ឈប់សំរាកចាប់ពី ០១ថ្ងៃ ឡើងទៅ ។
- មន្ត្រីរដ្ឋបាលស៊ីវិល ចំណុះសាលាខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានសុំច្បាប់ឈប់សំរាកចាប់ពី ០៧ថ្ងៃ ឡើងទៅ ។

- ប្រធានអង្គភាពនានា ក្នុងរចនាសម្ព័ន្ធសាលាខេត្ត ក្រុង មានសិទ្ធិអនុញ្ញាតច្បាប់ អោយមន្ត្រីរាជការ ក្រោមឱវាទ ក្នុងរយៈពេលមិនលើសពី ០១ថ្ងៃ ទៅ ០៣ថ្ងៃ ។
- ប្រធានពន្ធនាគារខេត្ត ក្រុង មានសិទ្ធិអនុញ្ញាតច្បាប់ឈប់សំរាក អោយមន្ត្រីក្រោមឱវាទ មិនលើសពី ០១ថ្ងៃ ។

៣. <u>សាលាស្រុក ខណ្ឌ:</u>

- អភិបាលស្រុក ខណ្ឌ មានសិទ្ធិអនុញ្ញាតច្បាប់ឈប់សំរាក ដល់មន្ត្រីរាជការក្រោមឱវាទទាំងអស់ ក្នុងរយៈពេល មិនលើសពី ០៣ថ្ងៃ ។
- ចំពោះស្មៀនឃុំ សង្កាត់ ដែលមានបំណងសុំច្បាប់ឈប់សំរាក មិនលើសពី ០១ថ្ងៃ ត្រូវសុំការអនុញ្ញាតច្បាប់ ពីមេឃុំ ចៅសង្កាត់ ។ បើចាប់ពី ០១ថ្ងៃទៅ ០៣ថ្ងៃ ត្រូវសុំការអនុញ្ញាតច្បាប់ពីអភិបាលស្រុក ខណ្ឌសាមី ដោយមានការឯកភាពពីមេឃុំ ចៅសង្កាត់ ។ ប៉ុន្តែបើរយៈពេលឈប់សំរាកលើសពី ០៤ថ្ងៃ ឡើងទៅ ត្រូវសុំការអនុញ្ញាតពីអភិបាលខេត្ត ក្រុងសាមី ដោយមានការឯកភាពពីមេឃុំ ចៅសង្កាត់ និង អភិបាលស្រុក ខណ្ឌសាមី ។

* *ដោយឡែក ការសុំអនុញ្ញាតច្បាប់ឈប់សំរាក ដើម្បីចេញទៅបរទេស ទោះបីមានលក្ខណៈជាផ្លូវការក្តី ឬក្រៅផ្លូវការក្តី ត្រូវសុំការអនុញ្ញាតច្បាប់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។*

គ. <u>**បែបបទនៃការសុំច្បាប់:**</u>

រាល់ការសុំច្បាប់ឈប់សំរាក ត្រូវស្នើសុំតាមលំដាប់ឋានានុក្រម និងតាមសមត្ថកិច្ចដូចបានកំណត់ខាងលើ ។ សាមីខ្លួនដែលស្នើសុំច្បាប់ឈប់សំរាក អាចឈប់សំរាកបាន លុះត្រាតែមានលិខិតអនុញ្ញាតច្បាប់ជាផ្លូវការ ដែលចេញដោយសមត្ថកិច្ច ដូចបានកំណត់ក្នុងចំណុច "ខ" ។ ការឈប់សំរាក មុនការចេញលិខិតអនុញ្ញាតច្បាប់ជាផ្លូវការ ត្រូវចាត់ទុកជាការឈប់ដោយឥតមានច្បាប់អនុញ្ញាត ។ ប៉ុន្តែក្នុងករណីប្រធានសក្តិ ឬមានធុរៈជាបន្ទាន់ ដែលពុំអាចរង់ចាំបាន សាមីខ្លួនត្រូវរាយការណ៍ ជូនប្រធានអង្គភាព អំពីមូលហេតុទាំងនោះ នៅពេលចូលបំពេញការងារវិញ ។ ក្នុងករណី នេះ មិនអនុញ្ញាតអោយឈប់សំរាកលើសពី ០៣ថ្ងៃឡើយ ។

*** លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីណែនាំនេះ ត្រូវចាត់ទុកជានិរាករណ៍ ។**

ទទួលបានសេចក្តីណែនាំនេះ សូមឯកឧត្តមអភិបាលគ្រប់ខេត្ត ក្រុង ឯកឧត្តមអគ្គនាយក ឯកឧត្តមអគ្គលេខាធិការ និង ឯកឧត្តមអគ្គាធិការ នៃក្រសួងមហាផ្ទៃ ចាត់ចែង ផ្សព្វផ្សាយ អនុវត្ត អោយមានប្រសិទ្ធិភាព ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០០៣*

**សម្តេចរដ្ឋមន្ត្រី**

ស ខេង

<u>**ចម្លងជូន :**</u>
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*
- *រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ*

*( <u>ជូនជ្រាបជាពត៌មាន</u> )*

- *គ្រប់សាលាខេត្ត ក្រុង*
- *អគ្គលេខាធិការដ្ឋាន*
- *អគ្គនាយកដ្ឋានរដ្ឋបាល*
- *អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល*

*( <u>ដើម្បីអនុវត្ត</u> )*

*ឯកសារ-កាលប្បវត្តិ*